## Expressing dislikes 1



នៅក្នុងភោជនីយដ្ឋាន

កុសល៖ ចង់ញ៉ាំអី កន្និកា?
កន្និកា៖ មានអីខ្លះអញ្ចេះ? ... ហៅតុំយ៉ាំ ម៉េចដែរ?
កុសល៖ តុំយ៉ាំហ្នឹង ជូរហឹរអីចឹងខ្ញុំដូចអត់សូវចូលចិត្តផង។
កន្និកា៖ អូ កុសលឯងអត់ចូលចិត្តតុំយ៉ាំអេអ៎? ហៅអីផ្សេងវិញទៅអីចឹង។ សម្លការីម៉េចដែរ?
កុសល៖ សម្លការី អត់អីទេ ខ្ញុំចូលចិត្តតាស។
កន្និកា៖ អូខេ យកសម្លការីមួយ។ ហើយអីទៀត?

វុទ្ធីត្រលប់ពីធ្វើការមកផ្ទះ

វុទ្ធី៖ ម៉ាក់ មានអីញ៉ាំអត់? ខ្ញុំឃ្លានអ៉ា។
ម្ដាយ៖ ម្ហូបអត់ទាន់ឆ្អិនផង។ ញ៉ាំចេកសិនទៅ ម៉េចដែរ?
វុទ្ធី៖ អត់ញ៉ាំអេ៉។ អត់ចូលចិត្តផង។
ម្ដាយ៖ ចាំម៉ាភ្លែតទៅអីចឹង។ ម្ហូបជិតឆ្អិនហើយ។
វុទ្ធី៖ ហ្នឹងហើយ អត់អីទេអីចឹង។ តាមសម្រួល។ ខ្ញុំទៅមុជទឹកសិន។

| | |
|---|---|
| កុសល, វុទ្ធី, កន្និកា | male, male, female Cambodian names |
| ភោជនីយដ្ឋាន | restaurant |
| ហៅ, យក | to order |
| តុំយ៉ាំ | Tom Yum soup |
| ... ម៉េចដែរ? | How about ... ? |
| អេអ៎ | spoken form of ទេឬ; used to confirm a negative statement |
| សម្លការី | curry |
| ម៉ាក់ | mom (when calling her, mostly used in the city; in the countryside: ម៉ែ) |
| អ៉ា | spoken form of ណាស់ = very much; the diacritic indicates rising intonation |
| ញ៉ាំចេកសិនទៅ | eat a banana first |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| អេ៎ | spoken form of ទេ; the diacritic indicates rising intonation |
| ចាំម៉ាភ្លែតទៅអីចឹង | then wait a bit... |
| ម្ហូបជិតឆ្អិនហើយ | the food is almost ready |
| តាមសម្រួល | Take your time! / No rush! |
| មុជទឹក | to take a shower or bath |

## Cultural notes

តើក្លិនផ្លែទុរេនឈ្ងុយឬក្រអូបទេសម្រាប់អ្នក? ជនជាតិផ្សេងភាគច្រើនមិនចូលចិត្តក្លិនរបស់ផ្លែទុរេននោះទេ។ ប៉ុន្តែ ជនជាតិខ្មែរជាទូទៅចូលចិត្តក្លិននិងរសជាតិផ្លែទុរេនខ្លាំងណាស់ ។
ទុរេនដែលល្បីថាឆ្ងាញ់គឺទុរេនមកពីខេត្តកំពត។

| | |
|---|---|
| ក្លិន | smell |
| ទុរេន | durian |
| ឈ្ងុយ | to smell delicious |
| ក្រអូប | aromatic, nice, pleasant; to smell delicious |
| រសជាតិ | taste |
| ល្បី | to be famous |
| ខេត្តកំពត | Kampot province |

## Additional dialogue

នៅក្នុងហាងលក់ខោអាវ

កញ្ញា៖ ជីវី ជួយមើលអាវមួយនេះមើល ខ្ញុំពាក់ទៅសមអត់?
ជីវី៖ សមតាស។ តែពណ៌ដូចមិនសូវស្អាត។ មានពណ៌ផ្សេងអត់?
កញ្ញា៖ មានតាស។ តែខ្ញុំអត់សូវចូលចិត្តពណ៌ឆើតៗអេ៎។
ជីវី៖ មិនជាឆើតអីទេ គ្រាន់តែយកពណ៌ស្រស់តិចទៅ។

| | |
|---|---|
| កញ្ញា, ជីវី | female Cambodian names |
| ... មើល | used to form a polite request |
| ពាក់ទៅសម | to fit, to suit |
| ... តាស | yes (used to affirm the preceding) |
| ពណ៌ឆើតៗ | bright color |
| មិនជាឆើតអីទេ | here: I didn’t mean you should choose a bright color |
| ពណ៌ស្រស់ | fresh color |
| ... តិចទៅ | you should ... (used in a suggestion or gentle order) |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.